ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៣០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃនិងសេវាកម្មអចលនវត្ថុ

### ទេសរដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើវិសោធនកម្មនៃច្បាប់ ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦៤៣ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យសហគ្រាស
- បានឃើញប្រកាសលេខ ១៣៣០ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងក្រុមហ៊ុន និងអតិថិជនដែលប្រើប្រាស់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ

- បង្កើនទំនុកចិត្តរបស់សាធារណជនចំពោះសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- អភិវឌ្ឍវិជ្ជាជីវៈវាយតម្លៃ និងសេវាកម្មអចលនវត្ថុប្រកបដោយចីរភាព
- រួមចំណែកទប់ស្កាត់សកម្មភាពសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មក្នុងវិស័យអចលនវត្ថុ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់យន្តការ វិធាន និងនីតិវិធីនៃការគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពពាក់ព័ន្ធនឹងអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ក្នុងក្របខណ្ឌនៃប្រកាសនេះ និយមន័យនៃបច្ចេកសព្ទ ត្រូវបានកំណត់ដូចខាងក្រោម÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **ក្រុមប្រឹក្សានីតិកម្ម** សំដៅដល់ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **អគ្គនាយកដ្ឋាន** សំដៅដល់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **នាយកដ្ឋាន** សំដៅដល់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **វិញ្ញាបនបត្រវិជ្ជាជីវៈ** សំដៅដល់លិខិតគតិយុត្តដែលចេញដោយក្រសួងជូនរូបវន្តបុគ្គលដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីប្រកបវិជ្ជាជីវៈជាអ្នកជំនាញវាយតម្លៃ ឬអ្នកជំនាញភ្នាក់ងារអចលនវត្ថុ
- **អាជ្ញាបណ្ណ** សំដៅដល់លិខិតគតិយុត្តដែលចេញដោយក្រសួងដើម្បីអនុញ្ញាតឱ្យនីតិបុគ្គលណាមួយដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីប្រកបសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- **សេវាកម្មវាយតម្លៃ** សំដៅដល់សេវាកម្មដែលធ្វើការវាយតម្លៃដើម្បីកំណត់តម្លៃលើទ្រព្យ និងអត្ថប្រយោជន៍ផ្សេងៗដែលតាំងនៅ ឬភ្ជាប់នឹងទ្រព្យនោះ។ ការវាយតម្លៃធ្វើឡើងដោយគោរពទៅតាមលក្ខខណ្ឌដូចមានកំណត់នៅក្នុងលិខិតផ្តល់អាណត្តិ តាមរយៈការចេញជារបាយការណ៍លាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីមតិយោបល់របស់អ្នកវាយតម្លៃទៅលើលទ្ធផលនៃការវាយតម្លៃនោះ
- **សេវាកម្មអចលនវត្ថុ** សំដៅដល់សេវាកម្មភ្នាក់ងារអចលនវត្ថុ និងសេវាកម្មគ្រប់គ្រងអចលនវត្ថុ
- **សេវាកម្មភ្នាក់ងារអចលនវត្ថុ** សំដៅដល់សេវាកម្មដែលធ្វើប្រតិបត្តិការលើអចលនវត្ថុរួមមាន÷ ការលក់-ទិញ និងជួលលើអចលនវត្ថុ
- **សេវាកម្មគ្រប់គ្រងអចលនវត្ថុ** សំដៅដល់សេវាកម្មដែលធ្វើការគ្រប់គ្រង ត្រួតពិនិត្យ និងធ្វើប្រតិបត្តិការផ្សេងលើអចលនវត្ថុទាំងឡាយណាដែលមានលក្ខណៈដូចជាៈ អគារស្នាក់នៅរួម បុរី អគារសហកម្មសិទ្ធិ និងអគារ ឬមជ្ឈមណ្ឌលពាណិជ្ជកម្មជាដើម ក្នុងនាមនិង/ឬជំនួសម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុនោះ ដោយ

ទទួលបានមកវិញនូវថ្លៃសេវាវិជ្ជាជីវៈ។ ការគ្រប់គ្រងនេះ មិនរាប់បញ្ចូលការគ្រប់គ្រងលើអចលនវត្ថុដែលត្រូវធ្វើអាជីវកម្មជាៈ សណ្ឋាគារ ផ្ទះសំណាក់ រោងចក្រ កំពង់ផែ កន្លែងវាយកូនគោល ការដ្ឋានយកថ្ម រោងភាពយន្ត ពហុកីឡាដ្ឋាន មជ្ឈមណ្ឌលកីឡា និងមន្ទីរពេទ្យឡើយ

- **ទ្រព្យ** សំដៅដល់ពាក្យបច្ចេកស័ព្ទម ដើម្បីសម្គាល់នូវប្រភេទ នៃទ្រព្យសកម្មមួយចំនួនដូចជាៈ អចលនវត្ថុ ទ្រព្យសកម្មរូបី ទ្រព្យសកម្មអរូបី ធុរកិច្ច និងអត្ថប្រយោជន៍ផ្សេងដែលតាំងនៅ ឬភ្ជាប់ទៅនឹងធុរកិច្ច
- **អចលនវត្ថុ** សំដៅដល់ដី និងវត្ថុផ្សេងៗរួមបញ្ចូលទាំងអ្វីគ្រប់យ៉ាងនៅលើដី និងក្រោមដី និងតាំងនៅ ឬភ្ជាប់ជាអចិន្ត្រៃយ៍ទៅនឹងដីនោះ ទោះបីជាកើតឡើងដោយធម្មជាតិ ឬកើតឡើងដោយមនុស្សក៏ដោយ
- **អ្នកវាយតម្លៃ** សំដៅដល់ក្រុមហ៊ុនវាយតម្លៃ និង/ឬអ្នកជំនាញវាយតម្លៃ
- **ក្រុមហ៊ុនវាយតម្លៃ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណសេវាកម្មវាយតម្លៃពីក្រសួង
- **អ្នកជំនាញវាយតម្លៃ** សំដៅដល់រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈពីក្រសួងដើម្បីផ្តល់សេវាកម្មវាយតម្លៃជូនអតិថិជនក្នុងនាមក្រុមហ៊ុនវាយតម្លៃ
- **ភ្នាក់ងារអចលនវត្ថុ** សំដៅដល់ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ និង/ឬអ្នកជំនាញភ្នាក់ងារអចលនវត្ថុ
- **ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណសេវាកម្មភ្នាក់ងារអចលនវត្ថុពីក្រសួង
- **អ្នកជំនាញភ្នាក់ងារអចលនវត្ថុ**សំដៅដល់រូបវន្តបុគ្គលដែលទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈពីក្រសួងដើម្បីផ្តល់សេវាកម្មភ្នាក់ងារអចលនវត្ថុជូនអតិថិជនក្នុងនាមក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ
- **ក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ** សំដៅដល់នីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណសេវាកម្មគ្រប់គ្រងអចលនវត្ថុពីក្រសួង
- **អតិថិជន** សំដៅដល់អ្នកដែលប្រើប្រាស់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- **មូលដ្ឋានកំណត់ថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈ** សំដៅដល់តារាងថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈសម្រាប់ការផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- **កម្រៃជើងសាវិជ្ជាជីវៈ** សំដៅដល់កម្រៃជើងសាដែលទទួលបានពីអតិថិជន ក្នុងការផ្តល់សេវាកម្មភ្នាក់ងារអចលនវត្ថុ
- **ថ្លៃសេវាវិជ្ជាជីវៈ** សំដៅដល់ថ្លៃសេវាដែលទទួលបានពីអតិថិជន ក្នុងការផ្តល់សេវាកម្មវាយតម្លៃ និង/ឬសេវាកម្មគ្រប់គ្រងអចលនវត្ថុ
- **សៀវភៅបន្ទុក** សំដៅដល់លក្ខខណ្ឌអនុវត្តចំពោះអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអ្នកកាន់អាជ្ញាបណ្ណដែលក្រសួងបានកំណត់ដោយអនុលោមតាមប្រកាសនេះ
- **ប្រាក់កក់សុវត្ថិភាព** សំដៅដល់ប្រាក់កក់ដែលបានដាក់តម្កល់ដោយអ្នកជួលសម្រាប់ធានាក្នុងការជួលស្នាក់នៅហើយត្រូវសងត្រឡប់មកអ្នកជួលវិញ ក្នុងករណីមិនមានការខូចខាត និង/ឬទូទាត់សំណងសម្រាប់ការខូចខាតក្នុងអំឡុងពេលស្នាក់នៅ

- **លិខិតផ្តល់អាណត្តិ** សំដៅដល់ការបញ្ជាក់អំពីការព្រមព្រៀងជាលាយលក្ខណ៍អក្សរលើលក្ខខណ្ឌដែលបានស្នើឡើងដោយអ្នកវាយតម្លៃ និងអតិថិជន ដើម្បីវាយតម្លៃទ្រព្យដែលជាកម្មវត្ថុនៃការវាយតម្លៃដោយមានចេញជារបាយការណ៍ ឬវិញ្ញាបនបត្រវាយតម្លៃ
- **កិច្ចព្រមព្រៀងភ្នាក់ងារ** សំដៅដល់ការព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលធ្វើឡើងរវាងភ្នាក់ងារអចលនវត្ថុជាមួយអតិថិជនដែលជាភាគីអ្នកលក់ ឬម្ចាស់កម្មសិទ្ធិ ក្នុងការផ្តល់សេវាកម្មភ្នាក់ងារអចលនវត្ថុ និងទទួលបានសិទ្ធិពីអ្នកលក់ ឬម្ចាស់កម្មសិទ្ធិ ក្នុងការយកអចលនវត្ថុទៅផ្សព្វផ្សាយដាក់លក់ ឬជួល
- **កិច្ចព្រមព្រៀងគ្រប់គ្រងអចលនវត្ថុ** សំដៅដល់ការព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលធ្វើឡើងរវាងក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុជាមួយអតិថិជនដែលជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុ ក្នុងការផ្តល់សេវាកម្មគ្រប់គ្រងអចលនវត្ថុក្នុងនាម និង/ឬជំនួសម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុនោះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**ប្រការ៥.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មាននាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាសេនាធិការក្នុងការបំពេញមុខងារ និងភារកិច្ចនេះ។

## ជំពូកទី៣
## អាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ

**ប្រការ៦.-**

រាល់ការធ្វើសេវាកម្មវាយតម្លៃ និង/ឬសេវាកម្មអចលនវត្ថុ ត្រូវមានអាជ្ញាបណ្ណអាជីវកម្ម និងវិញ្ញាបនបត្រវិជ្ជាជីវៈជាមុនដែលចេញដោយក្រសួង។

អាជ្ញាបណ្ណអាជីវកម្ម និងវិញ្ញាបនបត្រវិជ្ជាជីវៈ ចែកចេញទៅតាមប្រភេទដូចតទៅ÷

ក. អាជ្ញាបណ្ណអាជីវកម្ម ចែកចេញជា ០៣ (បី) ប្រភេទ ដែលនឹងត្រូវផ្តល់ជូននីតិបុគ្គលតាមប្រភេទដូចខាងក្រោម÷

- អាជ្ញាបណ្ណវាយតម្លៃ÷ ផ្តល់ជូនក្រុមហ៊ុន ឬសាខាក្រុមហ៊ុនដើម្បីធ្វើអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃជូនអតិថិជនជាថ្នូរនឹងថ្លៃសេវាវិជ្ជាជីវៈ

- អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ÷ ផ្តល់ជូនក្រុមហ៊ុន ឬសាខាក្រុមហ៊ុនដើម្បីធ្វើអាជីវកម្មផ្តល់សេវាកម្មភ្នាក់ងារអចលនវត្ថុជំនួសអតិថិជនជាថ្នូរនឹងកម្រៃជើងសាវិជ្ជាជីវៈ

- អាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ÷ ផ្តល់ជូនក្រុមហ៊ុន ឬសាខាក្រុមហ៊ុនដើម្បីធ្វើអាជីវកម្មផ្តល់សេវាកម្មគ្រប់គ្រងអចលនវត្ថុណាមួយក្នុងនាម និង/ឬជំនួសម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុជាថ្នូរនឹងថ្លៃសេវាវិជ្ជាជីវៈ។

ខ.វិញ្ញាបនបត្រវិជ្ជាជីវៈ ចែកចេញជា ០២ (ពីរ) ប្រភេទ ដែលនឹងត្រូវផ្តល់ជូនរូបវន្តបុគ្គលតាមប្រភេទដូចខាងក្រោម÷

- វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ÷ ផ្តល់ជូនរូបវន្តបុគ្គល ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដែលមានកំណត់ក្នុងប្រការ១១ នៃប្រកាសនេះ ដើម្បីប្រកបវិជ្ជាជីវៈជាអ្នកជំនាញវាយតម្លៃ

- វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ÷ ផ្តល់ជូនរូបវន្តបុគ្គល ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌ ដែលមានកំណត់ក្នុងប្រការ១១ នៃប្រកាសនេះ ដើម្បីប្រកបវិជ្ជាជីវៈជាអ្នកជំនាញភ្នាក់ងារ-អចលនវត្ថុ។

**ប្រការ៧.-**

អាជ្ញាបណ្ណអាជីវកម្ម ឬវិញ្ញាបនបត្រវិជ្ជាជីវៈគ្រប់ប្រភេទ មិនអាចធ្វើការផ្ទេរ ឬលក់បានទេ។

**ប្រការ៨.-**

អ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ មិនអាចផ្តល់សេវាកម្មវាយតម្លៃបានទេ។

អ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ និងអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃអាចឈរឈ្មោះជាតំណាងឱ្យក្រុមហ៊ុនវាយតម្លៃ ឬក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុបាន ប៉ុន្តែមិនអាចផ្តល់សេវាកម្មនេះក្នុងនាមបុគ្គលផ្ទាល់ខ្លួនបានទេ។

**ប្រការ៩.-**

បុគ្គលដែលមានបំណងប្រកបវិជ្ជាជីវៈផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណអាជីវកម្ម និងវិញ្ញាបនបត្រវិជ្ជាជីវៈ នៅនាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ១០ និងប្រការ១១ នៃប្រកាសនេះ។

**ប្រការ១០.-**

ដើម្បីទទួលបានអាជ្ញាបណ្ណវាយតម្លៃ អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ ឬអាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំមកនាយកដ្ឋាន ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ត្រូវមានអ្នកតំណាង ដើម្បីឈរឈ្មោះលើអាជ្ញាបណ្ណ ដែលត្រូវតែជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន និងត្រូវមានអាយុ យ៉ាងតិចចាប់ពី ២១ (ម្ភៃមួយ) ឆ្នាំឡើងទៅ

- បានចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា
- ត្រូវមានអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃយ៉ាងតិច ០២ (ពីរ) រូប ចំពោះក្រុមហ៊ុនវាយតម្លៃ និងមានអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុយ៉ាងតិច ០១ (មួយ) រូប ចំពោះក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ
- ត្រូវទិញធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈចេញដោយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយដែលមានតម្លៃសមមូលនឹងទឹកប្រាក់ចំនួន ២០០.០០០ (ពីររយពាន់)ដុល្លារអាមេរិក ចំពោះក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ លើកលែងតែក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ ដែលត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្តដោយមិនកំណត់ចំនួន
- ត្រូវមានផែនការអាជីវកម្មរយៈពេល ០៣ (បី)ឆ្នាំ។

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវបានកំណត់ដោយក្រសួង។

**ប្រការ១១.-**

ដើម្បីទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ ឬភ្នាក់ងារអចលនវត្ថុ រូបវន្តបុគ្គលត្រូវដាក់ពាក្យស្នើមកនាយកដ្ឋាន ដោយបំពេញលក្ខខណ្ឌដូចខាងក្រោម÷

- ត្រូវមានអាយុចាប់ពី ២១ (ម្ភៃមួយ) ឆ្នាំឡើងទៅ
- ត្រូវមានលិខិតថ្កោលទោសដែលចេញដោយក្រសួងយុត្តិធម៌ ឬចេញដោយប្រទេសសាមី ចំពោះជនបរទេស
- ត្រូវមានកម្រិតវប្បធម៌ចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ឬថ្នាក់ប្រហាក់ប្រហែលផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬច្បាប់ ចំពោះអ្នកស្នើសុំវិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ
- ត្រូវមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាបត្រ ឬសញ្ញាបត្រប្រហាក់ប្រហែល ឬវិញ្ញាបនបត្រ ឬសញ្ញាបត្រផ្នែកភ្នាក់ងារអចលនវត្ថុដែលចេញដោយគ្រឹះស្ថានបណ្តុះបណ្តាលណាមួយដែលទទួលស្គាល់ដោយក្រសួង ចំពោះអ្នកស្នើសុំវិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ
- មានបទពិសោធន៍ពាក់ព័ន្ធទៅនឹងវិស័យវាយតម្លៃ និង/ឬអចលនវត្ថុយ៉ាងតិច ០៦ (ប្រាំមួយ)ខែ

លក្ខខណ្ឌលម្អិតសម្រាប់ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបានកំណត់ដោយក្រសួង។

**ប្រការ១២.-**

ថ្លៃ និងសុពលភាពអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបានកំណត់ទៅតាមប្រភេទសេវាកម្មដូចខាងក្រោម÷

| ប្រភេទ | ថ្លៃអាជ្ញាបណ្ណ (ថ្មី និងបន្តសុពលភាព) | | | សុពលភាព |
|---|---|---|---|---|
| វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ | ២០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |
| វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ | ២០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |
| អាជ្ញាបណ្ណវាយតម្លៃ | ៥០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |
| អាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ | ៥០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |
| អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ | ៥០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |
| អាជ្ញាបណ្ណវាយតម្លៃ (សាខា) | ៣០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |
| អាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ (សាខា) | ៣០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |
| អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ (សាខា) | ៣០០.០០០ | រៀល/ | ០១ឆ្នាំ | ០៣ ឆ្នាំ |

ថ្លៃអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ ឬថ្លៃបន្តសុពលភាពអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ ដូចមានចែងក្នុងប្រការនេះ ត្រូវបង់រៀងរាល់ ០១ (មួយ)ឆ្នាំម្តងទៅក្នុងគណនីទោលរតនាគារជាតិនៅធនាគារជាតិនៃកម្ពុជា តាមដីកាអមរបស់នាយកដ្ឋាន។

អ្នកស្នើសុំ ត្រូវមកទទួលយកដីកាអមបង់ថ្លៃអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈប្រចាំឆ្នាំ ពីនាយកដ្ឋានឱ្យបាន ២១ (ម្ភៃមួយ) ថ្ងៃ មុនបំណាច់ឆ្នាំនីមួយៗនៃសុពលភាពដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈ។

អ្នកស្នើសុំ ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈឱ្យបាន ៣០ (សាមសិប) ថ្ងៃ មុនពេលដែលអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈផុតសុពលភាព។

**ប្រការ១៣.-**

ក្រសួងមានរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការក្នុងការពិនិត្យ និងសម្រេចផ្តល់ ឬមិនផ្តល់អាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ ឬមិនផ្តល់ ឬបន្តសុពលភាពអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារពាក់ព័ន្ធពេញលេញ និងគ្រប់ចំនួន។

**ប្រការ១៤.-**

ក្រុមហ៊ុន អាចបង្កើតសាខា ដើម្បីផ្តល់សេវាកម្មវាយតម្លៃ និង/ឬសេវាកម្មអចលនវត្ថុបាន លុះត្រាតែមានអាជ្ញាបណ្ណពីក្រសួងជាមុន។

នីតិវិធីនៃការបង្កើតសាខាក្រុមហ៊ុន ត្រូវបានកំណត់ក្នុងសៀវភៅបន្ទុក។

## ជំពូកទី៤

## កិច្ចដំណើរការអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ

### ផ្នែកទី១

### ភារកិច្ចរបស់អ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអ្នកកាន់អាជ្ញាបណ្ណ

**ប្រការ១៥.-**

ភារកិច្ចរបស់អ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈមានដូចតទៅ÷

- ត្រូវអនុវត្តក្រមសីលធម៌វិជ្ជាជីវៈអ្នកវាយតម្លៃឱ្យបានត្រឹមត្រូវ ចំពោះអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ
- ត្រូវអនុវត្តក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុឱ្យបានត្រឹមត្រូវចំពោះអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ
- ត្រូវអនុវត្តស្តង់ដារវាយតម្លៃឱ្យបានត្រឹមត្រូវ ចំពោះអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ
- ត្រូវទទួលខុសត្រូវចំពោះអតិថិជន និង/ឬក្រុមហ៊ុនពាក់ព័ន្ធនឹងការបំពេញសេវាកម្មរបស់ខ្លួន
- មិនត្រូវផ្តល់សេវាកម្មខុសពីជំនាញ ឬវិញ្ញាបនបត្រវិជ្ជាជីវៈដែលទទួលបាន
- ត្រូវបញ្ជាក់អត្តលេខវិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាបណ្ណសម្រាប់រាល់ការធ្វើទំនាក់ទំនង ឬការសរសេរឆ្លើយឆ្លង និងការផ្សព្វផ្សាយ ឬឃោសនាអំពីសេវាកម្ម ឬអចលនវត្ថុតាមប្រព័ន្ធផ្សព្វផ្សាយ និងមធ្យោបាយឃោសនាគ្រប់រូបភាព
- ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន និងនាមបណ្ណដែលចេញដោយក្រុមហ៊ុនដែលខ្លួនកំពុងបម្រើការដល់អតិថិជនរាល់ពេលប្រាស្រ័យទាក់ទងជាមួយអតិថិជន
- ត្រូវបម្រើការងារឱ្យក្រុមហ៊ុន ឬសាខាក្រុមហ៊ុនបានតែមួយគត់
- ត្រូវជូនដំណឹង និងដាក់ពាក្យជាលាយលក្ខណ៍អក្សរជាមុនទៅក្រុមហ៊ុនដែលកំពុងបម្រើការក្នុងករណីលាឈប់ពីការងារ
- មិនត្រូវផ្តល់គំនិត ឬយោបល់ដល់អតិថិជនលើសពីចំណេះដឹង ជំនាញ និងបទពិសោធន៍ដែលខ្លួនមាន
- មិនត្រូវបង្កវិវាទប្បដិវាទក្នុងការផ្តល់សេវាកម្មជាមួយនឹងអ្នកប្រកបវិជ្ជាវិជ្ជាជីវៈដូចគ្នា
- មិនត្រូវធ្វើសេចក្តីថ្លែង ឬចូលរួមក្នុងការបង្កើតឯកសារណាមួយដែលខ្លួនបានដឹងហើយថាវាជាឯកសារ ឬសេចក្តីថ្លែងដែលនាំឱ្យមានការយល់ខុស ឬជាការបោកបញ្ឆោត
- មិនត្រូវបន្តធ្វើសកម្មភាពប្រតិបត្តិការអាជីវកម្មផ្តល់សេវាកម្ម ក្នុងកំឡុងពេលត្រូវបានផ្អាកសកម្មភាពអាជីវកម្ម ឬព្យួរអាជ្ញាបណ្ណពីក្រសួង
- មិនត្រូវផ្តល់សេវាកម្មរបស់ខ្លួនដើម្បីបម្រើដល់សកម្មភាពសំអាតប្រាក់ ឬបម្រើដល់ផលប្រយោជន៍ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពបែបនេះ សាមីជន

ត្រូវវាយការណ៍ជាបន្ទាន់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ នៃធនាគារជាតិនៃកម្ពុជា ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

- ត្រូវប្រតិបត្តិវិជ្ជាជីវៈដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗដែលមានជាធរមាន។

**ប្រការ១៦.-**

កាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណមានដូចតទៅ៖

- ត្រូវអនុវត្តក្រមសីលធម៌វិជ្ជាជីវៈអ្នកវាយតម្លៃឱ្យបានត្រឹមត្រូវ ចំពោះក្រុមហ៊ុនវាយតម្លៃ
- ត្រូវអនុវត្តក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុឱ្យបានត្រឹមត្រូវ ចំពោះក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ
- ត្រូវអនុវត្តមូលដ្ឋានកំណត់ថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈឱ្យបានត្រឹមត្រូវ
- ត្រូវអនុវត្តស្តង់ដារវាយតម្លៃឱ្យបានត្រឹមត្រូវ ចំពោះក្រុមហ៊ុនវាយតម្លៃ
- ត្រូវមានលិខិតផ្តល់អាណត្តិ ចំពោះក្រុមហ៊ុនវាយតម្លៃ និងកិច្ចព្រមព្រៀងភ្នាក់ងារ ចំពោះក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ និងកិច្ចព្រមព្រៀងគ្រប់គ្រងអចលនវត្ថុ ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ សម្រាប់ការផ្តល់សេវាកម្មជូនអតិថិជន
- ត្រូវរៀបចំលិខិតផ្តល់អាណត្តិ កិច្ចព្រមព្រៀងភ្នាក់ងារ និងកិច្ចព្រមព្រៀងគ្រប់គ្រងអចលនវត្ថុជាលាយលក្ខណ៍អក្សរជាមួយអតិថិជន ព្រមទាំងមានការបញ្ជាក់ឱ្យបានច្បាស់លាស់នូវព័ត៌មានអប្បបរមា លក្ខខណ្ឌ និងកាតព្វកិច្ចដែលគូភាគីបានព្រមព្រៀងគ្នាដោយមានចុះហត្ថលេខា ឬស្នាមមេដៃទទួលស្គាល់ត្រឹមត្រូវដោយគូភាគីនៃកិច្ចសន្យាដូចមានកំណត់លម្អិតនៅក្នុងសៀវភៅបន្ទុក
- មិនត្រូវអនុញ្ញាតឱ្យបុគ្គលណាមួយផ្តល់សេវាកម្មខុសពីជំនាញ ឬវិញ្ញាបនបត្រវិជ្ជាជីវៈដែលបុគ្គលនោះទទួលបានការចុះបញ្ជីពីក្រសួងឡើយ ចំពោះក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ
- មិនត្រូវអនុញ្ញាតឱ្យបុគ្គលគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈធ្វើប្រតិបត្តិការជូនអតិថិជនឡើយ ចំពោះក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ
- មិនត្រូវអនុញ្ញាតឱ្យបុគ្គលគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈធ្វើការផ្សព្វផ្សាយ ឬឃោសនាអំពីសេវាកម្មរបស់ក្រុមហ៊ុន ឬអំពីអចលនវត្ថុរបស់អតិថិជនតាមប្រព័ន្ធផ្សព្វផ្សាយ ឬមធ្យោបាយឃោសនាគ្រប់រូបភាព
- មិនត្រូវផ្សព្វផ្សាយលក់អចលនវត្ថុ ដែលជាគម្រោងអភិវឌ្ឍលំនៅឋានដែលគ្មានអាជ្ញាបណ្ណអភិវឌ្ឍលំនៅឋានពីក្រសួង
- ត្រូវបញ្ជាក់អត្តលេខ និងប្រភេទអាជ្ញាបណ្ណសម្រាប់រាល់ការធ្វើទំនាក់ទំនង ឬការសរសេរឆ្លើយឆ្លង និងការផ្សព្វផ្សាយ ឬឃោសនាអំពីសេវាកម្ម ឬអចលនវត្ថុតាមប្រព័ន្ធផ្សព្វផ្សាយ និងមធ្យោបាយឃោសនាគ្រប់រូបភាព
- ត្រូវធ្វើអាជីវកម្មឱ្យបានត្រឹមត្រូវស្របតាមឈ្មោះនាមករណ៍ កម្មវត្ថុអាជីវកម្ម និងអាសយដ្ឋានទីតាំងដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណអាជីវកម្មដែលចេញដោយក្រសួង

- ត្រូវដាក់តាំងវិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាបណ្ណនៅទីកន្លែងដែលងាយមើលឃើញច្បាស់នៅក្នុងបរិវេណទីតាំងអាជីវកម្ម
- ត្រូវធានាថាអចលនវត្ថុដែលខ្លួនកំពុងគ្រប់គ្រងទទួលបានការថែទាំយ៉ាងល្អ ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ
- ត្រូវទទួលរ៉ាប់រងលើការរៀបចំកិច្ចសន្យាជួល និងជួលបន្តជាលាយលក្ខណ៍អក្សរជាមួយអ្នកជួល ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ
- ត្រូវទទួលខុសត្រូវលើការប្រមូលចំណូលបានពីការជួលជូនម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុ និងរក្សាទុកប្រាក់កក់សុវត្ថិភាពរបស់អ្នកជួលឱ្យមានប្រសិទ្ធភាពខ្ពស់ ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ
- ត្រូវញែកឱ្យដាច់ពីគ្នារវាងប្រាក់កក់សុវត្ថិភាពរបស់អ្នកជួល និងប្រាក់ចំណូលពីប្រតិបត្តិការជួលរបស់ម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុ ដើម្បីជៀសវាងការយកប្រាក់កក់សុវត្ថិភាពរបស់អ្នកជួលទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងផ្ទុយពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជួល ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ
- ត្រូវបង្វែរប្រាក់កក់សុវត្ថិភាពជូនទៅអ្នកជួលវិញ បន្ទាប់ពីការជួលត្រូវបានបញ្ចប់ និងក្រោយពីការទូទាត់រួចរាល់សម្រាប់ការខូចខាត ឬសំណងផ្សេងៗដែលអ្នកជួលត្រូវទទួលខុសត្រូវក្នុងអំឡុងពេលស្នាក់នៅ ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ
- ត្រូវធានាថាអ្នកបម្រើការងារពាក់ព័ន្ធនឹងការផ្ដល់សេវាកម្មរបស់ក្រុមហ៊ុនទាំងអស់មានបណ្ណសម្គាល់ខ្លួន និងនាមបណ្ណដែលចេញដោយក្រុមហ៊ុន
- ត្រូវណែនាំដល់អ្នកបម្រើការងារពាក់ព័ន្ធនឹងការផ្ដល់សេវាកម្មរបស់ក្រុមហ៊ុនទាំងអស់បង្ហាញបណ្ណសម្គាល់ខ្លួន និងនាមបណ្ណដល់អតិថិជនរាល់ពេលប្រាស្រ័យទាក់ទងជាមួយអតិថិជន
- ត្រូវរៀបចំ និងធ្វើកំណត់ត្រាអំពីព័ត៌មាន និងស្ថិតិអ្នកបម្រើការងាររបស់ក្រុមហ៊ុន កំណត់ត្រាពាក់ព័ន្ធនឹងការវាយតម្លៃទ្រព្យរបស់អតិថិជន រួមមានៈរបាយការណ៍វាយតម្លៃ សំណើរបស់អតិថិជន ទិន្នន័យ និងព័ត៌មាន ព្រមទាំងឯកសារវណ្ណបផ្សេងៗ ដែលជាមូលដ្ឋានក្នុងការសន្និដ្ឋាន និងការផ្ដល់គំនិតយោបល់លើលទ្ធផលនៃការវាយតម្លៃ និងឯកសារពាក់ព័ន្ធនឹងបញ្ជីស្នាមគណនេយ្យផ្សេងៗឱ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកនៅទីកន្លែងសុវត្ថិភាពឱ្យបានយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ចំពោះក្រុមហ៊ុនវាយ-តម្លៃ
- ត្រូវរៀបចំ និងធ្វើកំណត់ត្រាអំពីព័ត៌មាន និងស្ថិតិអ្នកបម្រើការងាររបស់ក្រុមហ៊ុន កំណត់ត្រាពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការអចលនវត្ថុរបស់អតិថិជន និងឯកសារពាក់ព័ន្ធនឹងបញ្ជីស្នាមគណនេយ្យផ្សេងៗឱ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកនៅទីកន្លែងសុវត្ថិភាពឱ្យបានយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ចំពោះក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ

- ត្រូវរៀបចំ និងធ្វើកំណត់ត្រាអំពីព័ត៌មាន និងស្ថិតិអ្នកបម្រើការងាររបស់ក្រុមហ៊ុន កំណត់ត្រាពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការគ្រប់គ្រងអចលនវត្ថុរបស់ម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុ និងឯកសារពាក់ព័ន្ធនឹងបញ្ជីស្មាមគណនេយ្យផ្សេងៗឱ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកនៅទីកន្លែងសុវត្ថិភាពឱ្យបានយ៉ាងតិច ០៥ (ប្រាំ)ឆ្នាំ ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ។

## ផ្នែកទី ២

## ការផ្លាស់ប្តូរទីតាំង នាមករណ៍ លក្ខន្តិកៈ ភាគហ៊ុនិក សមាជិកក្រុមប្រឹក្សាភិបាល និងអ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈ

**ប្រការ១៧.-**

រាល់ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគហ៊ុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈរបស់ក្រុមហ៊ុន/សាខាក្រុមហ៊ុន ត្រូវមានការឯកភាពជាមុនពីក្រសួង។

ក្រុមហ៊ុន ត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង មុននឹងធ្វើការផ្លាស់ប្តូរ។

ក្រសួង ត្រូវជូនដំណឹងអំពីការសម្រេចឯកភាព ឬជំទាស់ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលសមស្របណាមួយ គិតចាប់ពីកាលបរិច្ឆេទទទួលសំណើពីសាមីក្រុមហ៊ុន។

**ប្រការ១៨.-**

ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគហ៊ុនិក សមាជិកក្រុមប្រឹក្សាភិបាល អ្នកកាន់អាជ្ញាបណ្ណ ឬអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈរបស់ក្រុមហ៊ុន/សាខាក្រុមហ៊ុន ត្រូវផ្តល់ឯកសារដូចខាងក្រោម÷

**ក. ការស្នើសុំផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ក្រុមហ៊ុន/សាខាក្រុមហ៊ុន÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង ស្តីពីការស្នើសុំការផ្លាស់ប្តូរទីតាំងដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតឯកភាពពីអាជ្ញាធរដែនដីចំពោះទីតាំងអាជីវកម្មថ្មី
- លិខិតបញ្ជាក់ ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ ស្តីពីសារពើពន្ធ
- ឯកសារបញ្ជាក់សិទ្ធិកាន់កាប់អចលនវត្ថុទីតាំងថ្មី ឬកិច្ចសន្យាជួលទីតាំងថ្មី
- ឯកសារបញ្ជាក់អំពីការផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការផ្លាស់ប្តូរទីតាំងយ៉ាងតិច ០១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ ដើម្បីឱ្យអតិថិជនជ្រាបអំពីការផ្លាស់ប្តូរទីតាំងអាជីវកម្ម
- ឯកសារតម្រូវផ្សេងៗតាមការកំណត់របស់ក្រសួង។

**ខ. ការស្នើសុំផ្លាស់ប្តូរនាមករណ៍របស់ក្រុមហ៊ុន/សាខាក្រុមហ៊ុន÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង ស្តីពីការស្នើសុំការផ្លាស់ប្តូរនាមករណ៍ដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការផ្លាស់ប្តូរនាមករណ៍

- ឯកសារបញ្ជាក់អំពីការផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការផ្លាស់ប្តូរនាមករណ៍យ៉ាងតិច ០១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ ដើម្បីឱ្យអតិថិជនជ្រាបអំពីការផ្លាស់ប្តូរនាមករណ៍
- ឯកសារតម្រូវផ្សេងៗតាមការកំណត់របស់ក្រសួង។

**គ. ការស្នើសុំផ្លាស់ប្តូរភាគហ៊ុនិក ឬសមាជិកក្រុមប្រឹក្សាភិបាល÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួងស្តីពីការស្នើសុំការផ្លាស់ប្តូរភាគហ៊ុនិក ឬសមាជិកក្រុមប្រឹក្សាភិបាល ដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការផ្លាស់ប្តូរភាគហ៊ុនិក ឬសមាជិកក្រុមប្រឹក្សាភិបាល
- លិខិតទិញ-លក់ភាគហ៊ុនរបស់ភាគហ៊ុនិក សម្រាប់ការស្នើសុំផ្លាស់ប្តូរភាគហ៊ុនិក
- លិខិតបញ្ជាក់ ស្តីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ ស្តីពីសារពើពន្ធ សម្រាប់ការស្នើសុំផ្លាស់ប្តូរភាគហ៊ុនិក
- លិខិតថ្កោលទោស ឬលិខិតបញ្ជាក់កិរិយាមាយាទដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ឯកសារតម្រូវផ្សេងៗតាមការកំណត់របស់ក្រសួង។

**ឃ. ការស្នើសុំផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណអាជីវកម្ម÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង ស្តីពីការស្នើសុំការផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- អាជ្ញាបណ្ណអាជីវកម្ម
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការផ្លាស់ប្តូរអ្នកកាន់អាជ្ញាបណ្ណ
- លិខិតឯកភាពរបស់សាមីជនដែលនឹងត្រូវផ្លាស់ប្តូរចេញ
- ឯកសារតម្រូវផ្សេងៗតាមការកំណត់របស់ក្រសួង។

ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកកាន់អាជ្ញាបណ្ណថ្មី ត្រូវគោរពទៅតាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រការ១០ នៃប្រកាសនេះ។

**ង. ការស្នើសុំផ្លាស់ប្តូរអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈ÷**

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង ស្តីពីការស្នើសុំការផ្លាស់ប្តូរអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- វិញ្ញាបនបត្រវិជ្ជាជីវៈរបស់សាមីជនដែលនឹងត្រូវផ្លាស់ប្តូរ
- សេចក្តីសម្រេចរបស់ក្រុមហ៊ុនអំពីការអនុញ្ញាតលាឈប់ ឬបញ្ឈប់ពីការងារ
- លិខិតជូនដំណឹងរបស់អ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈអំពីការលាឈប់ពីការងារ (ប្រសិនបើមាន)

ការដាក់ពាក្យស្នើសុំចុះបញ្ជីវិញ្ញាបនបត្រវិជ្ជាជីវៈថ្មី ត្រូវគោរពទៅតាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រការ១១ នៃប្រកាសនេះ ។

## ផ្នែកទី ៣
## ការផ្អាក និងការបញ្ឈប់សកម្មភាពអាជីវកម្ម

**ប្រការ១៩.-**

ក្នុងករណីផ្អាកសកម្មភាពអាជីវកម្ម ក្រុមហ៊ុនត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតជាលាយលក្ខណ៍អក្សរមកក្រសួង ស្ដីពីការស្នើសុំផ្អាកសកម្មភាពអាជីវកម្មដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- លិខិតជូនដំណឹងទៅអាជ្ញាធរពន្ធដារមានសមត្ថកិច្ច ស្ដីពីការផ្អាកសកម្មភាពអាជីវកម្ម
- លិខិតបញ្ជាក់ ស្ដីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ ស្ដីពីសារពើពន្ធ
- ឯកសារបញ្ជាក់អំពីការផ្សព្វផ្សាយសេចក្ដីជូនដំណឹង ស្ដីពីការផ្អាកសកម្មភាពអាជីវកម្មយ៉ាងតិច ០១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទផ្សព្វផ្សាយ ដើម្បីឱ្យអតិថិជនជ្រាបអំពីការផ្អាកសកម្មភាពអាជីវកម្ម
- ឯកសារតម្រូវផ្សេងៗតាមការកំណត់របស់ក្រសួង។

ក្រសួង អនុញ្ញាតឱ្យក្រុមហ៊ុនផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនជាបណ្ដោះអាសន្នយ៉ាងយូរត្រឹម ០៤(បួន) ខែ ក្នុង ០១ (មួយ)ឆ្នាំ ឬត្រឹមសុពលភាពអាជ្ញាបណ្ណអាជីវកម្មដែលនៅសល់។

**ប្រការ២០.-**

ក្នុងករណីបញ្ឈប់សកម្មភាពអាជីវកម្ម ក្រុមហ៊ុនត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមកក្រសួង មុននឹងបញ្ឈប់សកម្មភាពអាជីវកម្ម ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចខាងក្រោម៖

- លិខិតស្នើសុំបញ្ឈប់សកម្មភាពអាជីវកម្មដោយមានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- អាជ្ញាបណ្ណអាជីវកម្មច្បាប់ដើម
- លិខិតបញ្ជាក់ ស្ដីពីការបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ ស្ដីពីសារពើពន្ធ
- ឯកសារបញ្ជាក់អំពីការផ្សព្វផ្សាយសេចក្ដីជូនដំណឹង ស្ដីពីការបញ្ឈប់សកម្មភាពអាជីវកម្មលើទំព័រសារ-ព័ត៌មានក្នុងស្រុកដោយទុករយៈពេលយ៉ាងតិច ០១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទចុះផ្សាយ ដើម្បីឱ្យអតិថិជនជ្រាបអំពីការបញ្ឈប់សកម្មភាពអាជីវកម្ម
- ឯកសារតម្រូវផ្សេងៗតាមការកំណត់របស់ក្រសួង។

**ប្រការ២១.-**

ក្រសួង ត្រូវចេញលិខិតបញ្ជាក់យល់ព្រម ឬបដិសេធសំណើរបស់ក្រុមហ៊ុនដោយបញ្ជាក់ហេតុផលត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានលិខិតស្នើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្ម និងឯកសារតម្រូវផ្សេងៗទៀត។

## ជំពូកទី៥
## ការត្រួតពិនិត្យតាមដាន

**ប្រការ២២.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិចាត់មន្ត្រីជំនាញដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តប្រកាសនេះ។

មន្ត្រីជំនាញ មានសិទ្ធិធ្វើត្រួតពិនិត្យលើក្រុមហ៊ុនវាយតម្លៃ ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ និងក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ និងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ២៣.-**

ក្រុមហ៊ុន ត្រូវផ្តល់របាយការណ៍មកក្រសួងឱ្យបានទៀងទាត់ និងទាន់ពេលវេលាទៅតាមកាលបរិច្ឆេទកំណត់ដូចខាងក្រោម÷

១.របាយការណ៍ប្រចាំខែឱ្យបានមុនថ្ងៃទី ១៥ (ដប់ប្រាំ) នៃខែបន្ទាប់

២.របាយការណ៍ប្រចាំត្រីមាសនៅរៀងរាល់បំណាច់ខែទី ១ (មួយ) នៃត្រីមាសបន្ទាប់

៣.របាយការណ៍ប្រចាំឆមាសនៅរៀងរាល់បំណាច់ខែទី ១ (មួយ) នៃឆមាសបន្ទាប់

៤.របាយការណ៍ប្រចាំឆ្នាំក្នុងរយៈពេល ០៣ (បី)ខែ គិតចាប់ពីការិយបរិច្ឆេទនៃឆ្នាំហិរញ្ញវត្ថុនីមួយៗ។

ទម្រង់គំរូរបាយការណ៍ខាងលើ នឹងមានផ្តល់ជូនដោយនាយកដ្ឋាន។

**ប្រការ២៤.-**

ក្រុមហ៊ុនវាយតម្លៃ ត្រូវផ្តល់របាយការណ៍មកក្រសួងដូចខាងក្រោម÷

១.របាយការណ៍ប្រចាំខែអំពីសកម្មភាពប្រតិបត្តិការវាយតម្លៃ

២.របាយការណ៍ប្រចាំត្រីមាសអំពីបច្ចុប្បន្នភាពតម្លៃអចលនវត្ថុ ដែលក្រុមហ៊ុនបាននិងកំពុងអនុវត្តតាមតំបន់នីមួយៗ

៣.របាយការណ៍ប្រចាំឆមាសអំពីចំនួន និងបម្រែបម្រួលចំនួនបុគ្គលិក (ភ្ជាប់ជាមួយរចនាសម្ព័ន្ធក្រុមហ៊ុន)

៤.របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**ប្រការ២៥.-**

ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ ត្រូវផ្តល់របាយការណ៍មកក្រសួងដូចខាងក្រោម÷

១.របាយការណ៍ប្រចាំខែអំពីសកម្មភាពប្រតិបត្តិការលក់-ទិញ និងជួលអចលនវត្ថុ

២.របាយការណ៍ប្រចាំត្រីមាសអំពីបច្ចុប្បន្នភាពតម្លៃលក់-ទិញ និងជួលអចលនវត្ថុដែលក្រុមហ៊ុនបាន និងកំពុងអនុវត្តតាមតំបន់នីមួយៗ

៣.របាយការណ៍ប្រចាំឆមាសអំពីចំនួន និងបម្រែបម្រួលចំនួនបុគ្គលិក (ភ្ជាប់ជាមួយរចនាសម្ព័ន្ធក្រុមហ៊ុន)

៤.របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**ប្រការ២៦.-**

ក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ ត្រូវផ្តល់របាយការណ៍មកក្រសួងដូចខាងក្រោម៖

១.របាយការណ៍ប្រចាំខែអំពីសកម្មភាពប្រតិបត្តិការគ្រប់គ្រងអចលនវត្ថុ

២.របាយការណ៍ប្រចាំត្រីមាសអំពីអត្រានៃការចូលស្នាក់នៅរបស់អ្នកជួល

៣.របាយការណ៍ប្រចាំឆមាសអំពីចំនួន និងបម្រែបម្រួលចំនួនបុគ្គលិក(ភ្ជាប់ជាមួយរចនាសម្ព័ន្ធក្រុមហ៊ុន)

៤.របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**ប្រការ២៧.-**

ក្រសួងមានសិទ្ធិតាំងតែងសវនករឯករាជ្យ ដើម្បីធ្វើសវនកម្មក្រុមហ៊ុនវាយតម្លៃ ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ និងក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុទាំងអស់ ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីពាក់ព័ន្ធនឹងទិន្នន័យ និង/ឬព័ត៌មានដែលផ្តល់ដោយក្រុមហ៊ុន ឬការប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។ រាល់ការចំណាយលើសវនករឯករាជ្យនេះ ជាបន្ទុករបស់ក្រុមហ៊ុន ក្នុងករណីរកឃើញថាក្រុមហ៊ុនមានកំហុស។ ដោយឡែក ក្នុងករណីរកឃើញថាក្រុមហ៊ុនមិនមានកំហុសទេ នោះការចំណាយលើសវនករឯករាជ្យនេះ ជាបន្ទុករបស់ក្រសួង។

## ជំពូកទី៦
## ការផ្សះផ្សា និងដោះស្រាយវិវាទ

**ប្រការ២៨.-**

វិវាទដែលកើតមានឡើងរវាងអតិថិជន និងក្រុមហ៊ុន ឬរវាងក្រុមហ៊ុន និងក្រុមហ៊ុនអាចជាកម្មវត្ថុនៃការសម្រុះសម្រួល និងផ្សះផ្សាដោយអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសម្រុះសម្រួល និងផ្សះផ្សាវិវាទ តាមការស្នើសុំរបស់ភាគីវិវាទ ក្នុងរយៈពេល ០២ (ពីរ) ខែ យ៉ាងយូរ។

ការផ្សះផ្សាវិវាទអាចឈានទៅដល់ការចុះកិច្ចព្រមព្រៀងផ្សះផ្សា ដែលត្រូវចុះហត្ថលេខាដោយគូភាគីវិវាទ ដោយមានប្រថាប់ត្រារបស់អគ្គនាយកដ្ឋាន។ កិច្ចព្រមព្រៀងផ្សះផ្សាមានអានុភាពអនុវត្តភ្លាមៗចំពោះគូភាគី។

**ប្រការ២៩-**

ក្រុមហ៊ុន ឬអតិថិជនដែលមិនពេញចិត្តចំពោះសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់ក្រសួង មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាមកក្រុមប្រឹក្សានីតិកម្ម មុននឹងអនុវត្តនីតិវិធីបណ្តឹងទៅតុលាការលើកលែងតែរឿងព្រហ្មទណ្ឌ។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដោះស្រាយបណ្តឹងក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃនៃថ្ងៃធ្វើការក្រោយពីទទួលបានពាក្យបណ្តឹងតវ៉ា ឬក្នុងរយៈពេលមួយសមស្រប។

ក្នុងការដោះស្រាយវិវាទ ក្រុមប្រឹក្សានីតិកម្ម អាចអញ្ជើញភាគីពាក់ព័ន្ធវិវាទ ដើម្បីសាកសួរ ឬផ្តល់ភស្តុតាងតាមការចាំបាច់។

សេចក្តីសម្រេច ស្តីពីការដោះស្រាយវិវាទ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់អំពីអង្គហេតុ សំអាងហេតុ និងការសន្និដ្ឋាន។

ក្នុងករណីមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្ម ភាគីវិវាទអាចដាក់ពាក្យបណ្តឹងតវ៉ា នៅតុលាការមានសមត្ថកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**ប្រការ៣០-**

ត្រូវបានចាត់ទុកជាអំពើល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះចំពោះអំពើដូចខាងក្រោម÷

- ប្រកបអាជីវកម្មផ្តល់សេវាកម្ម ដោយមិនអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកវាយតម្លៃ និងក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ
- ប្រកបអាជីវកម្មផ្តល់សេវាកម្មដោយគ្មានអាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈពីក្រសួង
- ក្លែងបន្លំអាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈ
- ប្រើប្រាស់អាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈផុតសុពលភាព
- យឺតយ៉ាវក្នុងការបង់ថ្លៃអាជ្ញាបណ្ណ /វិញ្ញាបនបត្រវិជ្ជាជីវៈប្រចាំឆ្នាំក្នុងរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ មុនបំណាច់ឆ្នាំនីមួយៗនៃសុពលភាពដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ /វិញ្ញាបនបត្រវិជ្ជាជីវៈ
- យឺតយ៉ាវក្នុងការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ /វិញ្ញាបនបត្រវិជ្ជាជីវៈក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ មុនពេលអាជ្ញាបណ្ណ /វិញ្ញាបនបត្រវិជ្ជាជីវៈផុតសុពលភាព
- ប្រកបអាជីវកម្មផ្តល់សេវាកម្មខុសពីនាមករណ៍ក្រុមហ៊ុន ឬកម្មវត្ថុអាជីវកម្ម ឬអាសយដ្ឋានទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ ដែលបានផ្តល់ជូនដោយក្រសួង
- ការបង្កើតសាខាក្រុមហ៊ុនដោយគ្មានការអនុញ្ញាតពីក្រសួងជាមុន
- ការផ្លាស់ប្តូរ ឬការកែប្រែរចនាសម្ព័ន្ធភាគហ៊ុនិក ឬសមាជិកក្រុមប្រឹក្សាភិបាល នាមករណ៍ ទីតាំងអាជីវកម្មក្រុមហ៊ុន/សាខាក្រុមហ៊ុនដោយគ្មានការអនុញ្ញាតពីក្រសួងជាមុន
- ការមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រការ១៥ និងប្រការ១៦ នៃប្រកាសនេះ
- ការយឺតយ៉ាវ ឬការខកខានមិនផ្តល់របាយការណ៍តាមការកំណត់របស់ក្រសួងដូចមានចែងក្នុងប្រការ ២៣ នៃប្រកាសនេះ
- ការក្លែងបន្លំ ឬបំពេញព័ត៌មានមិនបានពេញលេញនៅក្នុងរបាយការណ៍តម្រូវតាមការកំណត់របស់ក្រសួងដូចមានចែងក្នុងប្រការ២៤, ប្រការ២៥ និងប្រការ២៦ នៃប្រកាសនេះ
- ការមិនអនុវត្តតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រសួងដោយអនុលោមតាមច្បាប់ជាធរមាន។

**ប្រការ៣១.-**

ត្រូវចាត់ទុកថាមិនបានបំពេញត្រឹមត្រូវ ស្របតាមគោលការណ៍គ្រឹះជាមូលដ្ឋាននៃក្រមសីលធម៌វិជ្ជាជីវៈអ្នកវាយតម្លៃ និងក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ ចំពោះអំពើដូចខាងក្រោម÷

- ការអនុវត្តការងារដោយមិនអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្ត លក្ខខណ្ឌតម្រូវ នីតិវិធី និងកាតព្វកិច្ចនានាពាក់ព័ន្ធនឹងវិស័យអចលនវត្ថុ ដែលចេញដោយក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ
- ការធ្វើសកម្មភាពទាំងឡាយណាដែលឱ្យខូចខាតដល់ផលប្រយោជន៍សាធារណៈ ឬធ្វើឱ្យអាប់ឱនដល់វិជ្ជាជីវៈវាយតម្លៃ និង/ឬភ្នាក់ងារអចលនវត្ថុ
- ការផ្សព្វផ្សាយព័ត៌មាន ឬធ្វើសេចក្ដីថ្លែងជាសាធារណៈដែលមានលក្ខណៈបំផ្លើស ឬក្លែងបន្លំ ឬនាំឱ្យមានការយល់ខុសអំពីការវាយតម្លៃ និង/ឬប្រតិបត្តិការទិញ-លក់ និងជួលអចលនវត្ថុ ឬការងារទំនាក់ទំនងទាំងឡាយណាដែលពាក់ព័ន្ធនឹងការវាយតម្លៃ និង/ឬប្រតិបត្តិការទិញ-លក់ និងជួលអចលនវត្ថុនៅក្នុងទីផ្សារអចលនវត្ថុ
- ការផ្សព្វផ្សាយព័ត៌មានដែលមានលក្ខណៈបំផ្លើស ឬក្លែងបន្លំ ឬនាំឱ្យមានការយល់ខុស ឬបិទបាំងការពិតពាក់ព័ន្ធនឹងសេវាកម្ម សមត្ថភាព និងបទពិសោធន៍របស់ខ្លួន
- ការបង្កវាទប្បដិវាទជាមួយអ្នកប្រកបវិជ្ជាជីវៈដូចគ្នា
- ការអនុវត្តការយកថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈ មិនអនុលោមតាមមូលដ្ឋាននៃការកំណត់ថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈដែលកំណត់ដោយក្រសួង និងមិនមានការបញ្ជាក់ឱ្យច្បាស់លាស់អំពីវិធីសាស្ត្រនៃការគណនាថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈឱ្យបានត្រឹមត្រូវ
- ការមិនជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់អតិថិជនក្នុងករណីមានថ្លៃសេវា ឬកម្រៃជើងសាផ្សេងៗ ដែលមិនមែនជាថ្លៃសេវា ឬកម្រៃជើងសាវិជ្ជាជីវៈ
- ការទទួលថ្លៃសេវា ឬប្រាក់រង្វាន់ ឬកម្រៃជើងសា ឬអំណោយ ឬលាភសក្ការៈ ឬការលើកទឹកចិត្ត ឬអត្ថប្រយោជន៍ផ្សេងៗដោយផ្ទាល់ ឬប្រយោលពីបុគ្គល ឬភាគីដទៃទៀតដែលមានទាក់ទងនឹងការវាយតម្លៃ ឬការធ្វើប្រតិបត្តិការអចលនវត្ថុជូនអតិថិជន ដែលអាចធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងជាមួយនឹងអតិថិជន ដោយមិនមានការដឹងឮ និងយល់ព្រមពីអតិថិជន និងគ្រប់ភាគីដែលពាក់ព័ន្ធ
- ការធ្វើប្រតិបត្តិការវាយតម្លៃដែលលទ្ធផលមិនសមស្រប និងមិនឆ្លើយតបទៅនឹងគោលបំណងដែលបានស្នើឡើងដោយអតិថិជនដូចមានកំណត់នៅក្នុងលក្ខខណ្ឌនៃលិខិតផ្ដល់អាណត្តិ ចំពោះអ្នកវាយតម្លៃ
- ការប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ឬសម្រាប់ក្រុមហ៊ុន និងជាប្រយោជន៍ដល់តតិយជន ចំពោះអ្នកវាយតម្លៃ
- ការទទួលធ្វើប្រតិបត្តិការវាយតម្លៃដែលស្ថិតក្រោមការគំរាមកំហែង ឬមានភាពលំអៀងដែលអាចធ្វើឱ្យប៉ះពាល់ដល់គោលជំហរឯករាជ្យភាព និងអព្យាក្រឹត្យភាព ចំពោះអ្នកវាយតម្លៃ

- ការធ្វើប្រតិបត្តិការវាយតម្លៃលើទ្រព្យទាំងឡាយណា ដែលទំនងនឹងអាចកើតមាននូវទំនាស់ផលប្រយោជន៍ ដែលអាចធ្វើឱ្យខ្លួនជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ឬស្ថិតក្រោមឥទ្ធិពលណាមួយដែលធ្វើឱ្យមានការលំអៀងដល់សុភវិនិច្ឆ័យនៃវិជ្ជាជីវៈ ចំពោះអ្នកវាយតម្លៃ
- ការណែនាំអតិថិជនអំពីការកំណត់តម្លៃអចលនវត្ថុដែលត្រូវដាក់លក់ ដោយគ្មានការវាយតម្លៃតាមមូលដ្ឋាន និងវិធីសាស្ត្រត្រឹមត្រូវ ដែលឆ្លុះបញ្ចាំងអំពីថ្លៃស្របតាមស្ថានភាពទីផ្សារជាក់ស្តែង ចំពោះភ្នាក់ងារអចលនវត្ថុ
- ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធអចលនវត្ថុរបស់អតិថិជនដោយគ្មានការយល់ព្រមពីអតិថិជនជាមុន ឬមិនមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងភ្នាក់ងារ ចំពោះភ្នាក់ងារអចលនវត្ថុ
- ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធអចលនវត្ថុរបស់អតិថិជន ដែលមិនស្របទៅតាមតម្លៃកំណត់ ឬតាមលក្ខខណ្ឌដែលអតិថិជនបានណែនាំ និងបានព្រមព្រៀងគ្នា ចំពោះភ្នាក់ងារអចលនវត្ថុ
- ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធអចលនវត្ថុរបស់អតិថិជន តាមប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាពដែលធ្វើឡើងដោយបុគ្គលិក ឬបុគ្គលណាម្នាក់របស់ក្រុមហ៊ុនដែលគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈ ចំពោះភ្នាក់ងារអចលនវត្ថុ
- ការបន្តផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងអចលនវត្ថុរបស់អតិថិជន ដែលអស់សុពលភាពសម្រាប់ដាក់លក់ ឬជួល ក្នុងករណីកិច្ចព្រមព្រៀងភ្នាក់ងារបានបញ្ចប់ ចំពោះភ្នាក់ងារអចលនវត្ថុ
- ការធ្វើសេវាកម្ម ឬបន្តផ្តល់សេវាកម្មដោយធ្វើប្រតិបត្តិការទិញ-លក់ និងជួលលើអចលនវត្ថុណាមួយដែលពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ឬទំនងនឹងអាចកើតមាននូវទំនាស់ផលប្រយោជន៍ ចំពោះភ្នាក់ងារអចលនវត្ថុ
- ការធ្វើប្រតិបត្តិការទិញ-លក់ និងជួលលើអចលនវត្ថុដោយគ្មានការអនុញ្ញាត ឬគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជន ឬធ្វើប្រតិបត្តិការមិនស្របទៅតាមការណែនាំរបស់អតិថិជន ចំពោះភ្នាក់ងារអចលនវត្ថុ
- ការមិនផ្តល់ដំណឹងដល់អតិថិជន ឬភាគីណាមួយដទៃទៀតដែលមានការជាប់ព័ន្ធនឹងប្រតិបត្តិការទិញ-លក់ និងជួលអចលនវត្ថុ ដូចជាការទទួលធ្វើសេវាកម្មជាតំណាងឱ្យទាំងពីរភាគីគឺអ្នកលក់ និងអ្នកទិញ ឬម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុ និងអ្នកជួល ចំពោះភ្នាក់ងារអចលនវត្ថុ។

**ប្រការ៣២.-**

ក្រុមហ៊ុន/រូបវន្តបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តកំហុសដូចមានចែងក្នុងប្រការ៣០ និងប្រការ៣១ នៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មរដ្ឋបាល ដោយក្រសួង ដូចខាងក្រោម÷

- ព្រមានជាលាយលក្ខណ៍អក្សរ
- ហាមឃាត់ការធ្វើប្រតិបត្តិការ ឬរឹតត្បិតសកម្មភាពមួយចំនួន
- ព្យួរអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈបណ្តោះអាសន្នពី ០៦ (ប្រាំមួយ) ខែ ទៅ ០១ (មួយ) ឆ្នាំ

- ដកហូតអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈ/ បញ្ចប់សកម្មភាពអាជីវកម្មជាស្ថាពរ
- ព្យួរ ឬដកហូតអាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនមេ/សាខាក្រុមហ៊ុន
- ផ្សព្វផ្សាយជាសាធារណៈនូវអំពើបំពាននឹងបទប្បញ្ញត្តិនៃប្រកាសនេះ
- វិធានការផ្សេងៗទៀតតាមច្បាប់ជាធរមាន។

**ប្រការ៣៣.-**

ការប្រកបអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ ដោយគ្មានអាជ្ញាបណ្ណពីក្រសួង ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួង ចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ដើម្បីអាចប្រកបអាជីវកម្មឡើងវិញ ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួង។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង។

**ប្រការ៣៤.-**

ការក្លែងបន្លំអាជ្ញាបណ្ណ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

ការក្លែងបន្លំវិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវបញ្ឈប់សកម្មភាពអាជីវកម្មជាបន្ទាន់។

**ប្រការ៣៥.-**

ការយឺតយ៉ាវក្នុងការបង់ថ្លៃអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈប្រចាំឆ្នាំ ក្នុងរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ មុនបំណាច់ឆ្នាំនីមួយៗនៃសុពលភាព ដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥០.០០០ (ហាសិបពាន់) រៀល ក្នុង ០១ (មួយ) ថ្ងៃ។ ក្រុមហ៊ុន ត្រូវរួសរាន់មកទទួលដីកាអមបង់ថ្លៃអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈ។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង។

**ប្រការ៣៦.-**

ការយឺតយ៉ាវក្នុងការបន្តសុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ មុនពេលអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈផុតសុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥០.០០០ (ហាសិបពាន់) រៀល ក្នុង ០១ (មួយ) ថ្ងៃ។ ក្រុមហ៊ុន ត្រូវរួសរាន់មកដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈ។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង។

**ប្រការ៣៧.-**

ការប្រកបអាជីវកម្មផ្តល់សេវាកម្មជាមួយអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈផុតសុពលភាព ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ១០០.០០០ (មួយរយពាន់) រៀល ក្នុង ០១ (មួយ) ថ្ងៃ គិតក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ក្រោយពីអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈផុតសុពលភាព។ សម្រាប់រយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ ចំនួនទឹកប្រាក់ផាកពិន័យ នឹងត្រូវគុណទ្វេរដង។ ក្រុមហ៊ុន ត្រូវរួសរាន់មកដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈ។

ក្នុងករណីមិនរាងចាល ក្រសួងនឹងចាត់វិធានការដកហូតអាជ្ញាបណ្ណ/វិញ្ញាបនបត្រវិជ្ជាជីវៈ និងបញ្ឈប់សកម្មភាពអាជីវកម្មជាស្ថាពរ។

**ប្រការ៣៨.-**

ការប្រកបអាជីវកម្មផ្តល់សេវាកម្មខុសពីនាមករណ៍ក្រុមហ៊ុន ឬកម្មវត្ថុអាជីវកម្ម ឬអាសយដ្ឋានទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណ ដែលបានផ្តល់ជូនដោយក្រសួង ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ២.០០០.០០០ (ពីរលាន) រៀល ក្នុង ០១ (មួយ)ករណី និងត្រូវបញ្ឈប់សកម្មភាពនោះជាបន្ទាន់។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង។

**ប្រការ៣៩.-**

ការបង្កើតសាខាក្រុមហ៊ុនដោយគ្មានការអនុញ្ញាតពីក្រសួងជាមុន ត្រូវទទួលពិន័យអន្តរការណ៍ចំនួន ២.០០០.០០០ (ពីរលាន) រៀល ក្នុង ០១ (មួយ) សាខា និងត្រូវផ្អាកសកម្មភាពអាជីវកម្មសាខានោះជាបន្ទាន់។ ដើម្បីអាចបន្តសកម្មភាពអាជីវកម្មសាខាបាន ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់សាខាពីក្រសួង។

ក្នុងករណីមិនរាងចាល ក្រសួង នឹងព្យួរ ឬដកហូតអាជ្ញាបណ្ណប្រកបអាជីវកម្មក្រុមហ៊ុនមេ។

**ប្រការ៤០.-**

ការផ្លាស់ប្តូរ ឬការកែប្រែរចនាសម្ព័ន្ធភាគហ៊ុនិក ឬសមាជិកក្រុមប្រឹក្សាភិបាល នាមករណ៍ ទីតាំងអាជីវកម្មក្រុមហ៊ុន/សាខាក្រុមហ៊ុនដោយគ្មានគោលការណ៍ឯកភាពជាមុនពីក្រសួង ត្រូវទទួលពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល ក្នុង ០១ (មួយ) ករណី។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង។

**ប្រការ៤១.-**

ការមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងប្រការ១៥ និង ប្រការ១៦ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល ក្នុង ០១ (មួយ) ករណី។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេដង។

**ប្រការ៤២.-**

ការយឺតយ៉ាវ ឬការខកខានមិនផ្តល់របាយការណ៍តាមការកំណត់របស់ក្រសួងដូចមានចែងក្នុងប្រការ ២៣ ប្រការ២៤ ប្រការ២៥ និងប្រការ២៦ នៃប្រកាសនេះ ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួងចំនួន ៥០.០០០ (ហាសិបពាន់) រៀល ក្នុង ០១ (មួយ) ថ្ងៃ ឬក្នុង ០១ (មួយ) ករណី សម្រាប់រយៈពេល ៣០ (សាមសិប) ថ្ងៃដំបូង។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង ព្រមទាំងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ។

**ប្រការ៤៣.-**

ការអនុវត្តប្រាសចាក ឬបំពេញមិនបានត្រឹមត្រូវស្របតាមគោលការណ៍គ្រឹះជាមូលដ្ឋាននៃក្រមសីលធម៌វិជ្ជាជីវៈអ្នកវាយតម្លៃ និង/ឬក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ ដោយបានប្រព្រឹត្តនូវអំពើណាមួយដូចបានកំណត់ក្នុងប្រការ៣១ នៃប្រកាសនេះ ត្រូវទទួលរងពិន័យអន្តរការណ៍ពីក្រសួងចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ០១ (មួយ) ករណី។

ក្នុងករណីមិនរាងចាល ចំនួនទឹកប្រាក់ពិន័យអន្តរការណ៍នឹងត្រូវគុណទ្វេរដង ព្រមទាំងឈានដល់ការព្យួរ ឬដកហូតអាជ្ញាបណ្ណ/វិញ្ញាបនបត្រវិជ្ជាជីវៈ។

**ប្រការ៤៤.-**

ក្រសួង មានសិទ្ធិព្យួរអាជ្ញាបណ្ណអាជីវកម្ម និងវិញ្ញាបនបត្រវិជ្ជាជីវៈ ក្រោយពេលដែលក្រុមហ៊ុន/រូបវន្តបុគ្គលត្រូវបានពិន័យអន្តរការណ៍ និងព្រមានជាលាយលក្ខណ៍អក្សរក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនា
- បង្កើតសាខាដោយគ្មានការអនុញ្ញាតពីក្រសួងជាមុន
- ប្រកបអាជីវកម្មខុសពីកម្មវត្ថុនៃអាជ្ញាបណ្ណ/វិញ្ញាបនបត្រវិជ្ជាជីវៈដែលបានផ្តល់ជូនដោយចេតន
- រាងបណ្តឹងពាក់ព័ន្ធនឹងសកម្មភាព ឬលទ្ធផលនៃប្រតិបត្តិការអាជីវកម្មផ្តល់សេវាកម្ម
- បន្តអនុវត្តផ្ទុយនឹងប្រការ១០ ប្រការ១១ ប្រការ១៥ ប្រការ១៦ ប្រការ២៣ ប្រការ២៤ ប្រការ២៥ និងប្រការ២៦ នៃប្រកាសនេះ។

**ប្រការ៤៥.-**

ក្រសួងមានសិទ្ធិដកហូតអាជ្ញាបណ្ណអាជីវកម្ម និងវិញ្ញាបនបត្រវិជ្ជាជីវៈ នៅពេលដែលក្រុមហ៊ុន/រូបវន្តបុគ្គលបន្តប្រព្រឹត្តល្មើសក្រោយត្រូវបានពិន័យអន្តរការណ៍ ឬព្រមានជាលាយលក្ខណ៍អក្សររួចរាល់ហើយ ក្នុងករណីណាមួយដូចខាងក្រោម÷

- ខកខានមិនបានផ្តល់របាយការណ៍ប្រចាំខែដោយចេតនា ឬអចេតនា ចាប់ពី ០៦ (ប្រាំមួយ)ខែឡើងទៅ ក្រោយពីព្រមានជាលាយលក្ខណ៍អក្សរលើកទី ២ (ពីរ) នៅតែមិនរាងចាលទៀត
- ខកខានមិនបានបំពេញកាតព្វកិច្ចពន្ធដារត្រឹមត្រូវតាមច្បាប់ ស្តីពីសារពើពន្ធលើសពី ០៦ (ប្រាំមួយ) ខែឡើងទៅ
- ប្រើប្រាស់អាជ្ញាបណ្ណ /វិញ្ញាបនបត្រវិជ្ជាជីវៈ ផុតសុពលភាពលើសពី ០៣ (បី)ខែ
- ក្រោយពីទទួលការព្រមានជាលាយលក្ខណ៍អក្សរលើកទី ២ (ពីរ) ហើយនៅតែបន្តការប្រកបអាជីវកម្មផ្តល់សេវាកម្មខុសពីនាមករណ៍ក្រុមហ៊ុន ឬកម្មវត្ថុអាជីវកម្ម ឬអាសយដ្ឋានទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាបណ្ណដែលបានផ្តល់ជូនដោយក្រសួងទៀត
- យឺតយ៉ាវក្នុងការបន្តសុពលភាពអាជ្ញាបណ្ណ /វិញ្ញាបនបត្រវិជ្ជាជីវៈលើសពី ០៣ (បី)ខែ ក្រោយពេលអាជ្ញាបណ្ណ /វិញ្ញាបនបត្រវិជ្ជាជីវៈនោះផុតសុពលភាព
- បង្កើតសាខាលើសពី ០២ (ពីរ) សាខាឡើងទៅដោយគ្មានការអនុញ្ញាតពីក្រសួងជាមុន
- បានធ្វើសកម្មភាព ឬបានរួមចំណែកទៅនឹងសកម្មភាពលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច
- គ្មានសកម្មភាពប្រតិបត្តិការ ឬប្រកាសសកម្មភាពប្រតិបត្តិការសូន្យជាបៀងរាល់ខែក្នុងរយៈពេល ០៣ (បី)ឆ្នាំជាប់ៗគ្នា
- ការមិនបំពេញកាតព្វកិច្ចបង់ថ្លៃអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រវិជ្ជាជីវៈប្រចាំឆ្នាំ ឬបង់ប្រាក់ពិន័យតាមការជូនដំណឹងរបស់ក្រសួង

- ផុតកាលវសានតនៃការព្យួរដូចមានចែងក្នុងប្រការ៤៤ នៃប្រកាសនេះ ដោយមូលហេតុនៃការព្យួររបស់ក្រុមហ៊ុន/រូបវន្តបុគ្គលនៅតែមិនទាន់បានដោះស្រាយ
- ការប្រព្រឹត្តមិនរាងចាល ក្រោយការព្រមានជាលាយលក្ខណ៍អក្សរលើកទី ២ (ពីរ) ចំពោះការក្លែងបន្លំ ឬបំពេញព័ត៌មានមិនបានពេញលេញនៅក្នុងទម្រង់របាយការណ៍តម្រូវ តាមការកំណត់របស់ក្រសួង ដូចមានចែងក្នុងប្រការ២៤ ប្រការ២៥ និងប្រការ២៦ នៃប្រកាសនេះ
- ការប្រព្រឹត្តមិនរាងចាល ក្រោយការព្រមានជាលាយលក្ខណ៍អក្សរលើកទី ២ (ពីរ) ចំពោះការអនុវត្ត មិនអនុលោមតាមគោលការណ៍គ្រឹះជាមូលដ្ឋាននៃក្រមសីលធម៌វិជ្ជាជីវៈអ្នកវាយតម្លៃ និងក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារអចលវត្ថុ ដោយបន្តប្រព្រឹត្តល្មើស ដូចមានចែងនៅក្នុងប្រការ៣១ នៃប្រកាសនេះ។
- នៅបន្តអនុវត្តផ្ទុយនឹងប្រការ៧ ប្រការ១០ ប្រការ១១ និងប្រការ១៧ នៃប្រកាសនេះ ក្រោយពីអាជ្ញាបណ្ណ/វិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបានព្យួររួច។

ក្រសួង នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរចំនួន ៣០ (សាមសិប) ថ្ងៃ មុននឹងព្យួរ ឬដកហូតអាជ្ញាបណ្ណ/វិញ្ញាបនបត្រវិជ្ជាជីវៈពីក្រុមហ៊ុន /រូបវន្តបុគ្គលដែលប្រព្រឹត្តខុស។

ក្រុមហ៊ុន /រូបវន្តបុគ្គល ដែលត្រូវបានព្យួរ ឬដកហូតអាជ្ញាបណ្ណ/ វិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបញ្ឈប់សកម្មភាពអាជីវកម្មក្នុងវិស័យអចលនវត្ថុចាប់ពីកាលបរិច្ឆេទចេញលិខិតជាលាយលក្ខណ៍អក្សរដោយក្រសួង។ ក្រុមហ៊ុន /រូបវន្តបុគ្គល ដែលត្រូវបានព្យួរសកម្មភាពអាជីវកម្ម អាចចាប់ផ្តើមដំណើរការឡើងវិញបាន លុះត្រាតែមានលិខិតជាលាយលក្ខណ៍អក្សរពីក្រសួង។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**ប្រការ៤៦.-**

អាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈ ដែលក្រសួងផ្តល់ជូន មុនពេលដាក់ឱ្យអនុវត្តប្រកាសនេះ នៅបន្តមានសុពលភាពរហូតដល់ផុតកាលកំណត់សុពលភាពរបស់អាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈនោះ។

**ប្រការ៤៧.-**

ប្រកាសនេះ ត្រូវចាប់អនុវត្តក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីចូលជាធរមាន។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ៤៨.-**

ប្រកាសលេខ ១៤២ សហវ.ប្រក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាបណ្ណផ្នែកសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ និងសារាចរណែនាំលេខ ០០២ សហវ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការអនុវត្តប្រកាស ស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាបណ្ណផ្នែកសេវាកម្ម

វាយតម្លៃ និងសេវាកម្មអចលនវត្ថុ ព្រមទាំងរាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤៩.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហ៊ុន និងរូបវន្តបុគ្គលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង/ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី ខេត្ត
- ដូចប្រការ៤៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ